**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ........៧៦២........ក. ស. ភ.

ថ្ងៃព្រហស្បតិ៍ ៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ
## ការងារជួសជុល ប្រព័ន្ធទឹកស្អាត ទឹកពន្លត់អគ្គីភ័យ និងផ្គត់ផ្គង់ថាមពលអគ្គិសនី តភ្ជាប់ទៅនាវាទេសចរណ៍ជាតិ/អន្តរជាតិ ជំហានទី១ នៅចំណតផែពហុបំណងTS៣

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលលើការងារជួសជុល ប្រព័ន្ធទឹកស្អាត ទឹកពន្លត់អគ្គីភ័យ និងផ្គត់ផ្គង់ថាមពលអគ្គិសនី តភ្ជាប់ទៅនាវាទេសចរណ៍ជាតិ/អន្តរជាតិ ជំហានទី១ នៅចំណតផែពហុបំណងTS៣។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃឯកសារដេញថ្លៃមានដាក់លក់ នៅអង្គភាពលទ្ធកម្ម នៃកំពង់ផែស្វយ័តភ្នំពេញ ដែលមានអាសយដ្ឋានអគារ លេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី...៣០...ខែ...ឧសភា... ឆ្នាំ២០២៥ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនងលេខ ០១០ ៤៤៤ ៦៤១)។

កាលបរិច្ឆេទឈប់ទទួលពាក្យសំណើដេញថ្លៃនៅ**វេលាម៉ោង**..១៤:៣០..**នាទី ថ្ងៃទី**..៣០..**ខែ**..មិថុនា..**ឆ្នាំ២០២៥។**

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង**..១៤:៣០..**នាទី ថ្ងៃទី**..៣០..**ខែ**..មិថុនា.......**ឆ្នាំ២០២៥។**

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ជួន សុខេម**

**ចម្លងជូន**
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ



ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh